**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ៤៥៥,៩៧ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីដីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៥គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ



www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៥៥៨អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ដីទំហំ ៩៥៥,៩៧ ហិកតា ចេញពីដីតម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៩៣២,៩៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២២,៩៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិតាម៉ិញ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២:** ត្រូវបានប្រគល់អាណត្តិកាន់កាប់និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រងនិងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩៥គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិតាម៉ិញ ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣:** ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។



www.pheakdeylaw.com

**មាត្រា ៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ..៥៦៧..អនក្រ.បក........................ចុះថ្ងៃទី..០៧...ខែវិច្ឆិកា..ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ៤៥៥,៩៧ ហិកតា ចេញពីដែនដីគម្របព្រៃឈើឆ្នាំ២០០២ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ឆ្វៀលដីទំហំ ៤៣២,៩៨ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែងចំនួន ១៩៥ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ២២,៩៩ ហិកតា នៅភូមិតាមិញ ឃុំសង្កែសាធប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ




តារាងចំណុចនិយាមការ

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 410623 | 1289290 | 63 | 412814 | 1289970 | 125 | 412353 | 1288220 |
| 2 | 410633 | 1289300 | 64 | 412816 | 1289920 | 126 | 412336 | 1288240 |
| 3 | 410676 | 1289340 | 65 | 412837 | 1289900 | 127 | 412288 | 1288270 |
| 4 | 410652 | 1289420 | 66 | 412877 | 1289960 | 128 | 412166 | 1288310 |
| 5 | 410710 | 1289510 | 67 | 412976 | 1290140 | 129 | 412116 | 1288300 |
| 6 | 410758 | 1289580 | 68 | 413171 | 1290180 | 130 | 412017 | 1288240 |
| 7 | 410796 | 1289620 | 69 | 413226 | 1290190 | 131 | 412027 | 1288200 |
| 8 | 410860 | 1289620 | 70 | 413225 | 1290280 | 132 | 412025 | 1288160 |
| 9 | 410957 | 1289620 | 71 | 413235 | 1290330 | 133 | 411988 | 1288110 |
| 10 | 411044 | 1289610 | 72 | 413303 | 1290430 | 134 | 411910 | 1288100 |
| 11 | 411121 | 1289600 | 73 | 413337 | 1290420 | 135 | 411888 | 1288110 |
| 12 | 411166 | 1289600 | 74 | 413373 | 1290490 | 136 | 411763 | 1288050 |
| 13 | 411240 | 1289600 | 75 | 413452 | 1290540 | 137 | 411758 | 1288040 |
| 14 | 411240 | 1289580 | 76 | 413536 | 1290320 | 138 | 411771 | 1288000 |
| 15 | 411234 | 1289540 | 77 | 413587 | 1290200 | 139 | 411795 | 1287940 |
| 16 | 411430 | 1289530 | 78 | 413444 | 1290100 | 140 | 411772 | 1287920 |
| 17 | 411437 | 1289530 | 79 | 413503 | 1290030 | 141 | 411724 | 1287890 |
| 18 | 411483 | 1289530 | 80 | 413489 | 1289890 | 142 | 411646 | 1287900 |
| 19 | 411518 | 1289540 | 81 | 413460 | 1289630 | 143 | 411617 | 1287880 |
| 20 | 411519 | 1289540 | 82 | 413399 | 1289580 | 144 | 411549 | 1287850 |
| 21 | 411560 | 1289540 | 83 | 413494 | 1289520 | 145 | 411374 | 1287840 |
| 22 | 411609 | 1289540 | 84 | 413483 | 1289490 | 146 | 411332 | 1287830 |
| 23 | 411636 | 1289540 | 85 | 413578 | 1289490 | 147 | 411267 | 1287830 |
| 24 | 411683 | 1289540 | 86 | 413747 | 1289390 | 148 | 411179 | 1287830 |
| 25 | 411723 | 1289540 | 87 | 413669 | 1289300 | 149 | 411007 | 1287790 |
| 26 | 411773 | 1289540 | 88 | 413563 | 1289360 | 150 | 410979 | 1287760 |
| 27 | 411775 | 1289590 | 89 | 413533 | 1289270 | 151 | 410773 | 1287700 |
| 28 | 411771 | 1289610 | 90 | 413480 | 1289260 | 152 | 410596 | 1287630 |
| 29 | 411776 | 1289700 | 91 | 413641 | 1289070 | 153 | 410517 | 1287600 |
| 30 | 411805 | 1289690 | 92 | 413434 | 1289080 | 154 | 410477 | 1287680 |
| 31 | 411822 | 1289700 | 93 | 413421 | 1289060 | 155 | 410468 | 1287580 |
| 32 | 411960 | 1289700 | 94 | 413266 | 1289090 | 156 | 410432 | 1287570 |
| 33 | 411963 | 1289640 | 95 | 413276 | 1289020 | 157 | 410390 | 1287560 |
| 34 | 412078 | 1289670 | 96 | 413152 | 1288990 | 158 | 410344 | 1287560 |
| 35 | 412102 | 1289690 | 97 | 413084 | 1288950 | 159 | 410336 | 1287560 |
| 36 | 412137 | 1289670 | 98 | 413038 | 1288920 | 160 | 410386 | 1287740 |
| 37 | 412142 | 1289670 | 99 | 413024 | 1288950 | 161 | 410412 | 1287820 |
| 38 | 412157 | 1289680 | 100 | 412993 | 1288920 | 162 | 410448 | 1287940 |
| 39 | 412184 | 1289710 | 101 | 412988 | 1288860 | 163 | 410481 | 1287990 |
| 40 | 412231 | 1289730 | 102 | 412910 | 1288770 | 164 | 410470 | 1288010 |
| 41 | 412223 | 1289730 | 103 | 412860 | 1288760 | 165 | 410478 | 1288010 |
| 42 | 412239 | 1289810 | 104 | 412839 | 1288740 | 166 | 410502 | 1288010 |
| 43 | 412338 | 1289810 | 105 | 412775 | 1288730 | 167 | 410542 | 1288200 |
| 44 | 412359 | 1289810 | 106 | 412704 | 1288730 | 168 | 410598 | 1288190 |
| 45 | 412358 | 1289840 | 107 | 412671 | 1288710 | 169 | 410698 | 1288190 |
| 46 | 412351 | 1289920 | 108 | 412650 | 1288700 | 170 | 410647 | 1288190 |
| 47 | 412373 | 1289910 | 109 | 412624 | 1288640 | 171 | 410792 | 1288170 |
| 48 | 412396 | 1289920 | 110 | 412650 | 1288560 | 172 | 410803 | 1288190 |
| 49 | 412395 | 1289960 | 111 | 412704 | 1288520 | 173 | 410806 | 1288200 |
| 50 | 412402 | 1289970 | 112 | 412733 | 1288480 | 174 | 410814 | 1288240 |
| 51 | 412440 | 1289960 | 113 | 412710 | 1288400 | 175 | 410814 | 1288240 |
| 52 | 412486 | 1289950 | 114 | 412689 | 1288410 | 176 | 410832 | 1288330 |
| 53 | 412543 | 1289970 | 115 | 412649 | 1288460 | 177 | 410581 | 1288350 |
| 54 | 412588 | 1290050 | 116 | 412548 | 1288480 | 178 | 410616 | 1288480 |
| 55 | 412589 | 1290050 | 117 | 412524 | 1288460 | 179 | 410648 | 1288610 |
| 56 | 412629 | 1290040 | 118 | 412455 | 1288450 | 180 | 410655 | 1288640 |
| 57 | 412645 | 1290050 | 119 | 412436 | 1288390 | 181 | 410674 | 1288710 |
| 58 | 412657 | 1290080 | 120 | 412436 | 1288360 | 182 | 410700 | 1288820 |
| 59 | 412656 | 1290090 | 121 | 412420 | 1288360 | 183 | 410727 | 1288940 |
| 60 | 412711 | 1290100 | 122 | 412404 | 1288300 | 184 | 410680 | 1289020 |
| 61 | 412827 | 1290100 | 123 | 412393 | 1288260 | 185 | 410630 | 1289110 |
| 62 | 412823 | 1290000 | 124 | 412381 | 1288240 | 186 | 410573 | 1289200 |




www.pheakdeylaw.com